UNITED NATIONS
CAMBODIA

**សេចក្តីប្រកាសព័ត៌មាន**
**ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២២**

# អ្នកសម្របសម្រួលថ្មីរបស់អង្គការសហប្រជាជាតិ លោក ចូសែហ្វ ស្កូយ៉ែរ អញ្ជើញជួបសវនាការនិងបង្ហាញសារតាំងជូនក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីទទួលបានការតែងតាំងពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឋានៈជា អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា លោក ចូសែហ្វ ស្កូយ៉ែរ សញ្ញាតិលុចឹសំបួរ បានប្រគល់សារតាំងជូន ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងខណៈដែលលោកបានចូលកាន់តួនាទីរបស់លោកជាផ្លូវការនៅក្នុងប្រទេសកម្ពុជា។

ក្នុងជំនួបសវនាការនេះ អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ បានសម្តែងការកោតសរសើរចំពោះភាពជាដៃគូដ៏ល្អរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ព្រមទាំងបានពិភាក្សាគ្នាអំពីឱកាសនាពេលអនាគតក្នុងបរិបទ នៃការរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី របស់អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ ២០២៤-២០២៨។ លោក ស្កូយ៉ែរ ក៏បានទទួលស្គាល់ និងកោតសរសើរផងដែរចំពោះការរួមចំណែករបស់ប្រទេសកម្ពុជានៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ចាប់តាំងពីឆ្នាំ ២០០៦។

*«ខ្ញុំទន្ទឹងរង់ចាំ សហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូនានានៅក្នុងការរៀបចំ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការថ្មីរបស់អង្គការសហប្រជាជាតិជាមួយប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០២៤-២០២៨ ដើម្បីជួយគាំទ្រឲ្យប្រទេសនេះ សម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ តាមរយៈកិច្ចសហប្រតិបត្តិការរបស់យើង យើងនឹងផ្តោតលើវិស័យអាទិភាពសំខាន់ៗមួយចំនួន ដែលឥទ្ធិពលជាវិជ្ជមាន ដូចជាការអភិវឌ្ឍមូលធនមនុស្ស ការដោះស្រាយបញ្ហាវិសមភាព សេដ្ឋកិច្ចបៃតង និងការផ្លាស់ប្តូរបែបឌីជីថល ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ និងធានាថា គ្មាននរណាម្នាក់ត្រូវបានទុកចោល»* ប្រសាសន៍របស់លោក ស្កូយ៉ែរ។

ក្រុមគ្រួសារអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា រួមមានភ្នាក់ងារមូលនិធិ និងកម្មវិធីចំនួនជាង ២០ ។ អស់រយៈពេលជាងបីទសវត្សរ៍មកនេះ អង្គការសហប្រជាជាតិនៅកម្ពុជាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងប្រជាជនកម្ពុជា ដើម្បីចូលរួម ការអភិវឌ្ឍប្រកបដោយចីរភាព ការពង្រឹងភាពធន់ និរន្តរភាពសន្តិភាព និងការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

###

សម្រាប់សំនួរសារព័ត៌មាន សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រ នៃការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជាតាមរយៈ
sreysros.keo@un.org ឬ ០១១ ៨៨ ៥៧ ៦៦។